ទីស្តីការក្រសួងយុត្តិធម៌
លេខ ០៨.សរ-៩៧

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើចំពោះ**

**លោកប្រធានតុលាការខេត្ត ក្រុង**

**ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** ការកាន់កាប់ ប្រើប្រាស់ ការលាក់ទុក និងការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះខុសច្បាប់ ។

ខ្ញុំសូមជម្រាបលោកថា ចាប់តាំងពីថ្ងៃនេះតទៅ ជនណាដែលកាន់កាប់ ប្រើប្រាស់ លាក់ទុក និងដឹកជញ្ជូនអាវុធយុទ្ធភណ្ឌ នឹងគ្រឿងផ្ទុះផ្សេងៗ ខុសច្បាប់ ជននោះត្រូវជាប់ចោទនឹងផ្តន្ទាទោសតាមមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដូចធម្មតា ។

ម៉្យាងទៀត បទល្មើសនេះ ជាបទល្មើសជាក់ស្តែង អយ្យការត្រូវសហការណែនាំមន្ត្រីនគរបាលយុត្តិធម៌ឱ្យចាត់វិធានការរឿងបែបនេះភ្លាមៗ ជូនមកអយ្យការ ។ បន្ទាប់មកអយ្យការត្រូវធ្វើការចោទប្រកាន់ដាក់ជូនទៅតុលាការជំនុំជម្រះភ្លាម តាមរបៀបចាត់ការបទល្មើសជាក់ស្តែង ដោយមិនបាច់ជូនទៅចៅក្រមស៊ើបអង្កេត ដើម្បីស៊ើបសួរនាំអោយខាតពេលយូរនោះទេ ។

ក្រសួងយុត្តិធម៌ សង្ឃឹមថាអស់លោកនឹងចាត់ការតាមការណែនាំនៃសារាចរនេះអោយបានម៉ឺងម៉ាត់ និងហ្មត់ចត់ជាទីបំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
- ប្រធានតុលាការកំពូល
- អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- ប្រធានសាលាឧទ្ធរណ៍
- អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍